ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្តីជូនដំណឹង

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមជម្រាបជូន **សាធារណជន សាស្ត្រាចារ្យ និងនិស្សិត** ជ្រាបថា ក្រសួងបានដាក់ឱ្យដំណើរការគម្រោងនៃគំនិតផ្តួចផ្តើមសាលារៀនកម្ពុជា ក្នុងគោលបំណងចូលរួមរៀបចំផែនការមេសាលារៀន ដោយរួមបញ្ចូលផ្នត់គំនិតនៃការអភិវឌ្ឍទីក្រុង លំហសាធារណៈ គំនិតច្នៃប្រឌិត ការកែលម្អសោភណភាព មុខងារអគារ របៀបរៀបរយ សុខភាពសិក្សា និងប្រយោជន៍សហគមន៍ ស្របតាមគោលនយោបាយការរៀបចំដែនដី និងនគរូបនីយកម្ម។

គួសបញ្ជាក់ថា គំនិតផ្តួចផ្តើមសាលារៀនកម្ពុជា មានចំនួន ២គម្រោង រួមមាន÷ (១). គម្រោងនិក្ខេបបទស្រាវជ្រាវលើប្រធានបទផែនការមេសាលារៀន និង(២). គម្រោងប្រកួតប្រជែងគំនិតកែលម្អសោភណភាពមុខងារអគារ និងលំហបៃតងសាលារៀន ដែលគម្រោងទាំងនេះសុទ្ធតែផ្តល់ឱកាសដល់និស្សិតកំពុងសិក្សាជំនាញស្ថាបត្យកម្ម និងជំនាញរៀបចំក្រុង នគរូបនីយកម្ម ដើម្បីចូលរួមចលនាប្រកួតប្រជែងស្នាដៃឆ្នើមតាមរយៈការរៀបចំផែនការមេសាលារៀន ក្នុងការលើកកម្ពស់សោភណភាព លំហបៃតងសាលារៀន សុខភាពសិក្សា និងការកំណត់មុខងារអគារ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សាធារណជន សាស្ត្រាចារ្យ និងនិស្សិត** ជ្រាបជាព័ត៌មានសម្រាប់និស្សិត និងគ្រឹះស្ថានអប់រំសិក្សាដែលមានចំណាប់អារម្មណ៍លើគម្រោងនេះ សូមស្កេន QR code ខាងក្រោម ដើម្បីទទួលបានព័ត៌មានលម្អិត នីតិវិធី អត្ថប្រយោជន៍ និងការដាក់ពាក្យប្រកួតប្រជែង ឱ្យបានត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥។

ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០២៥

QR សម្រាប់ព័ត៌មានលម្អិត

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com


គំនិតផ្តួចផ្តើម
សាលារៀនកម្ពុជា
គម្រោង
ចលនាប្រកួតប្រជែងស្នាដៃឆ្នើម
តាមរយៈការរៀបចំផែនការមេ
សាលារៀន
គម្រោងទី១ គម្រោងនិក្ខេបបទ ស្រាវជ្រាវលើប្រធានបទផែនការមេសាលារៀន
គម្រោងទី២ គម្រោងប្រកួតប្រជែងគំនិតកែលម្អសោភណភាព មុខងារអគារ និងលំហបៃតងសាលារៀន
ស្កេន QR Code សម្រាប់ព័ត៌មានលម្អិត
Gazette-យុវជន